ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ១៨៤ MIH / 2016

# ប្រកាស
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួល អន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសេចក្តីសម្រេចលេខ ៦០ សសរ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.**_

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២. | ឯកឧត្តម សាត សាមី | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. | ឯកឧត្តមនាយឧត្តមសេនីយ៍ យុន វុធ | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៤. | ឯកឧត្តម នាង ផែន | ទីប្រឹក្សាគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | អនុប្រធាន |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

| | | | |
|---|---|---|---|
| ៥. | លោកឧត្តមសេនីយ៍ត្រី សឿន ផល្លា | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦. | ឯកឧត្តម ជា ថោយ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧. | ឯកឧត្តម ឡៅ ទិព្វសីហា | អនុរដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨. | ឯកឧត្តម ស៊ា ហួង | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩. | ឯកឧត្តម នុត អ៊ុនវ៉ែណា | ជំនួយការអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០. | ឯកឧត្តម ឧត្តមនីយ៍ឯក ឡាយ គឹមលី | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ១១. | ឯកឧត្តម ឧត្តមនីយ៍ឯក កេ ដា | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិអាវុធគីមីនៃក្រសួងការពារជាតិ | សមាជិក |
| ១២. | លោក គឹម មាសសុខសីហា | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. | លោក ស្រី សុទ្ធា | អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤. | លោក ផា អេងវ៉េង | ប្រធាននាយកដ្ឋានរបបគយនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥. | លោក ថុល ចាន់ថន | ប្រធាននាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាននៃក្រសួងបរិស្ថាន | សមាជិក |
| ១៦. | លោកបណ្ឌិត សង់ ស៊ីណាវិទ្យ | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. | លោក ម៉ៃ សំអូន | នាយករងនៃនាយកដ្ឋានប្រតិបត្តិការទំនិញទូទៅនៃកំពង់ផែស្វយ័តព្រះសីហនុ | សមាជិក |
| ១៨. | លោក ទា វណ្ណារ៉េត | ប្រធានការិយាល័យសន្តិសុខនៃកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ១៩. | ឯកឧត្តម ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |

**ប្រការ២._**

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ច ដូចតទៅ៖

- បំពេញការងារជាសេនាធិការជូនរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាពីកាតព្វកិច្ច និងតម្រូវការរបស់ជាតិលើការចូលរួមគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ សម្រាប់ជាមូលដ្ឋាននៃការធ្វើសេចក្តីសម្រេចចិត្ត និងជំរុញការចូលរួមអនុវត្តន៍ឲ្យមានប្រសិទ្ធភាពខ្ពស់
- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិលើការគ្រប់គ្រងទំនិញគ្រោះថ្នាក់ឲ្យទទួលបាននូវសុវត្ថិភាព ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- រៀបចំគ្រប់គ្រង និងបង្កើតប្រព័ន្ធទិន្នន័យជាតិ ស្តីពីទំនិញគ្រោះថ្នាក់



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

- ប្រមូលគ្រប់ព័ត៌មានដែលទាក់ទងនឹងទំនិញគ្រោះថ្នាក់ ព្រមទាំងធ្វើការពិនិត្យ វិភាគ និងវាយតម្លៃទិន្នន័យនៃភាពមិនប្រក្រតីក្នុងការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន ការនាំចូល ការនាំចេញ និងការស្តុកទុកទំនិញគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័នរបស់ខ្លួន ហើយរាយការណ៍ជាប្រចាំតាមរបៀបរបបការងារដែលប្រធានបានកំណត់
- ផ្លាស់ប្តូរ និងផ្តល់ព័ត៌មានជាប្រចាំរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសព័ត៌មានដែលទាក់ទងដល់ការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន និងការស្តុកទុកទំនិញគ្រោះថ្នាក់
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋាន ច្បាប់ និងផែនការសកម្មភាពជាតិ ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងការត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- សិក្សា និងវាយតម្លៃពីបញ្ហាប្រឈម និងពីចំណុចខ្វះខាតលើការគ្រប់គ្រង និងការត្រួតពិនិត្យទំនិញគ្រោះថ្នាក់នៅក្នុងក្របខណ្ឌជាតិ និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធជ្រាប ពីតម្រូវការចាំបាច់បន្ថែមសម្រាប់ឈានទៅគ្រប់គ្រង និងត្រួតពិនិត្យ
- រៀបចំ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័នពាក់ព័ន្ធជ្រាប និងដើម្បីមានវិធានការសមស្របក្នុងករណីចាំបាច់ និងទាន់ពេលវេលា
- ជួយសម្របសម្រួលដល់ការងារទំនាក់ទំនងរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិកក្រុមការងារលើរាល់បញ្ហាទាក់ទងទៅនឹងការគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- សម្របសម្រួលដល់បណ្តាគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានាក្នុងក្របខណ្ឌជាតិ ដែលពាក់ព័ន្ធនឹងការចូលរួមអនុវត្តអនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- លើកឡើងនូវវិធានការចាំបាច់នានា ដើម្បីធានាដល់ការគ្រប់គ្រង និងត្រួតពិនិត្យការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន និងការស្តុកទុកទំនិញគ្រោះថ្នាក់
- ផ្តល់ប្រឹក្សាយោបល់ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការជានាបង្ការគ្រោះថ្នាក់។

**ប្រការ៣._**

សមាជិកគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ត្រូវអនុវត្តតាមភារកិច្ចដែលមានចែងក្នុងប្រការ ២ ខាងលើ និងត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងអាចប្រគល់សិទ្ធិជូនអនុប្រធាន ដឹកនាំកិច្ចប្រជុំជំនួសក្នុងពេល អវត្តមាន ឬក្នុងករណីចាំបាច់។

**ប្រការ៤._**

ត្រូវបានបង្កើតលេខាធិការដ្ឋាន នៅវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីជាជំនួយការ និងធ្វើការសម្របសម្រួលរាល់សកម្មភាពការងាររបស់គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង គ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | ប្រធាន |
| ២. | លោក ចិន សេងហ៊ាង | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | អនុប្រធាន |



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

| | | | |
|---|---|---|---|
| ៣. | លោក ម៉ៅ ធីរ៉ា | ប្រធាននាយកដ្ឋានបញ្ញត្តកម្ម | សមាជិក |
| ៤. | លោក អ៊ិន សំបូរ | ប្រធានមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា | សមាជិក |
| ៥. | លោក ខៀវ វិចិត្រ | ប្រធានការិយាល័យនៃនាយកដ្ឋានបញ្ញត្តកម្ម | សមាជិក |
| ៦. | លោក ជា ថារក្ស | ប្រធានការិយាល័យនៃនាយកដ្ឋានបញ្ញត្តកម្ម | សមាជិក |

**ប្រការ៥.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.**_

គ្រប់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងសមាសភាពដូចមានឈ្មោះក្នុងប្រការ១ និងប្រការ៤ ព្រមទាំងអង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នដូចប្រការ១
- អគ្គលេខាធិការរាជរដ្ឋាភិបាល

  *«ដើម្បីជូនជ្រាប»*

-សាមីខ្លួនដូចប្រការ១ និងប្រការ៤

  *«ដើម្បីអនុវត្ត»*

-ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com